**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលរាជធានីភ្នំពេញ**
លេខ : ១០០/២១ សសរ

# សេចក្តីសម្រេច
## ស្តីពី
## ការដាក់ចេញវិធានការរដ្ឋបាល សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដោយបែងចែក ជា "តំបន់ក្រហម" "តំបន់លឿងទុំ" និង "តំបន់លឿង" សម្រាប់រយៈពេល ៧ (ប្រាំពីរ) ថ្ងៃ គិតចាប់ពីម៉ោងសូន្យ នាថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១

## អភិបាល នៃគណៈអភិបាលរាជធានីភ្នំពេញ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៩/០០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ២០១៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២១/០០៤ ចុះថ្ងៃទី១១ ខែមីនា ឆ្នាំ២០២១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការសុខាភិបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ.បក ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២១ ស្តីពីវិធានការរដ្ឋបាល ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត
- បានឃើញសេចក្តីសម្រេចលេខ ៦១ សសរ ចុះថ្ងៃទី៣ ខែឧសភា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបញ្ចប់ការបន្តបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល ចាប់ពីថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២១ តទៅ ដោយជំនួសមកវិញនូវវិធានការថ្មី សំដៅបង្ការការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ របស់គណៈអភិបាលរាជធានីភ្នំពេញ សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងរបស់គណៈអភិបាលខេត្តកណ្តាល សម្រាប់ភូមិសាស្ត្រក្រុងតាខ្មៅ
- បានឃើញសេចក្តីណែនាំលេខ ០៣ សណន ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការពង្រឹងការអនុវត្តវិធានការចាំបាច់មួយចំនួន ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បន្ទាប់ពីរាជរដ្ឋាភិបាលបានសម្រេចបញ្ចប់ការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល
- យោងភារកិច្ចចាំបាច់ចំពោះមុខ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ : (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ : (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

## សម្រេច

**ប្រការ១.-**

ត្រូវបានដាក់ចេញវិធានការរដ្ឋបាល សម្រាប់ភូមិសាស្ត្ររាជធានីភ្នំពេញ ដោយត្រូវបែងចែកជា **៣ (បី) តំបន់** ដូចខាងក្រោម៖

- "**តំបន់ក្រហម**" ៖ សំដៅដល់ភូមិសាស្ត្រដែលមានការឆ្លងរាលដាលធ្ងន់ធ្ងរនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍
- "**តំបន់លឿងទុំ**" ៖ សំដៅដល់ភូមិសាស្ត្រដែលមានការឆ្លងរាលដាលកម្រិតមធ្យមនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍
- "**តំបន់លឿង**" ៖ សំដៅដល់ភូមិសាស្ត្រដែលមានការឆ្លងរាលដាលកម្រិតស្រាលនៃជំងឺកូវីដ-១៩ ក្នុងសហគមន៍។

**"តំបន់ក្រហម"** និង **"តំបន់លឿងទុំ"** ជាភូមិសាស្ត្រដែលត្រូវអនុវត្តវិធានការបិទខ្ទប់ ដូចមានចែងក្នុងប្រការ៣ និងប្រការ៤ នៃសេចក្តីសម្រេចនេះ។ ដោយឡែក **"តំបន់លឿង"** មិនស្ថិតនៅក្នុងភូមិសាស្ត្របិទខ្ទប់ ប៉ុន្តែ ត្រូវអនុវត្តវិធានការរដ្ឋបាល ដូចមានចែងក្នុងប្រការ៥ នៃសេចក្តីសម្រេចនេះ។

ផែនទីនៃការកំណត់ភូមិសាស្ត្ររាជធានីភ្នំពេញ ជា **"តំបន់ក្រហម" "តំបន់លឿងទុំ" និង "តំបន់លឿង"** ត្រូវបានភ្ជាប់មកជាឧបសម្ព័ន្ធនៃសេចក្តីសម្រេចនេះ។

**ប្រការ២.-**

វិធានការរដ្ឋបាលដែលត្រូវអនុវត្ត ក្នុងភូមិសាស្ត្ររាជធានីភ្នំពេញ ត្រូវចាប់ផ្តើមអនុវត្តសម្រាប់រយៈពេល **៧ (ប្រាំពីរ) ថ្ងៃ គិតចាប់ពីម៉ោងសូន្យ នាថ្ងៃទី៦ ខែឧសភា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី១២ ខែឧសភា ឆ្នាំ២០២១** ក្នុងនោះ ការកំណត់ជា **"តំបន់ក្រហម" "តំបន់លឿងទុំ" និង "តំបន់លឿង"** មានដូចខាងក្រោម៖

| **ល.រ** | **មូលដ្ឋានខណ្ឌ** | **ការកំណត់ភូមិសាស្ត្ររាជធានីភ្នំពេញ** | | |
|---|---|---|---|---|
| | | **តំបន់លឿង** | **តំបន់លឿងទុំ** | **តំបន់ក្រហម** |
| ១ | **ខណ្ឌចំការមន** | - សង្កាត់ទួលទំពូងទី១<br>- សង្កាត់ទួលទំពូងទី២<br>- សង្កាត់ផ្សារដើមថ្កូវ<br>- សង្កាត់ទន្លេបាសាក់<br>- សង្កាត់បឹងត្របែក | -គ្មាន- | -គ្មាន- |
| | | **តំបន់លឿង** | **តំបន់លឿងទុំ** | **តំបន់ក្រហម** |
| ២ | **ខណ្ឌដូនពេញ** | - សង្កាត់ផ្សារចាស់<br>- សង្កាត់បឹងរាំង<br>- សង្កាត់ចតុមុខ<br>- សង្កាត់ជ័យជំនះ<br>- សង្កាត់ស្រះចក<br>- សង្កាត់វត្តភ្នំ<br>- សង្កាត់ផ្សារកណ្តាលទី១<br>- សង្កាត់ផ្សារកណ្តាលទី២<br>- សង្កាត់ផ្សារថ្មីទី១<br>- សង្កាត់ផ្សារថ្មីទី២<br>- សង្កាត់ផ្សារថ្មីទី៣ | -គ្មាន- | -គ្មាន- |



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ: (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

| | | | | |
|---|---|---|---|---|
| ៣ | **ខណ្ឌ៧មករា** | **តំបន់លឿង** | **តំបន់លឿងទុំ** | **តំបន់ក្រហម** |
| | | - សង្កាត់អូរឫស្សីទី១<br>- សង្កាត់អូរឫស្សីទី២<br>- សង្កាត់អូរឫស្សីទី៣<br>- សង្កាត់អូរឫស្សីទី៤<br>- សង្កាត់មនោរម្យ<br>- សង្កាត់មិត្តភាព<br>- សង្កាត់បឹងព្រលិត<br>- សង្កាត់វាលវង់ (លើកលែង ប្លុកបុរីកីឡា "ចំនួន ៨ អគារ") | -គ្មាន- | - សង្កាត់វាលវង់ (ប្លុកបុរីកីឡា "ចំនួន ៨ អគារ") |
| ៤ | **ខណ្ឌទួលគោក** | **តំបន់លឿង** | **តំបន់លឿងទុំ** | **តំបន់ក្រហម** |
| | | - សង្កាត់ផ្សារដេប៉ូទី១<br>- សង្កាត់ផ្សារដេប៉ូទី២<br>- សង្កាត់ផ្សារដេប៉ូទី៣<br>- សង្កាត់ទឹកល្អក់ទី១<br>- សង្កាត់ទឹកល្អក់ទី២<br>- សង្កាត់ទឹកល្អក់ទី៣<br>- សង្កាត់បឹងកក់ទី១<br>- សង្កាត់បឹងកក់ទី២ (លើកលែង ភូមិ១៧ ភូមិ២២ និងភូមិ២៣)<br>- សង្កាត់ផ្សារដើមគរ (លើកលែង ភូមិ១ ភូមិ២ ភូមិ៣ ភូមិ៥ ភូមិ៦ និងភូមិ៧)<br>- សង្កាត់បឹងសាឡាង (លើកលែង ភូមិ៧ ភូមិ៩ ភូមិ១០ ភូមិ១១ ភូមិ១២ ភូមិ១៣ ភូមិ១៤ ភូមិ១៥ ភូមិ១៧ ផ្នែកខ្លះនៃភូមិ៣ ផ្នែកខ្លះនៃភូមិ៥ ផ្នែកខ្លះនៃភូមិ៦ និងផ្នែកខ្លះនៃភូមិ១៦) | - សង្កាត់បឹងកក់ទី២ (ភូមិ១៧ និងភូមិ២២)<br>- សង្កាត់បឹងសាឡាង (ភូមិ៧ ភូមិ៩ ភូមិ១១ ភូមិ១២ ភូមិ១៣ ភូមិ១៥ ភូមិ១៧ ផ្នែកខ្លះនៃភូមិ៣ ផ្នែកខ្លះនៃភូមិ៥ ផ្នែកខ្លះនៃភូមិ៦ និងផ្នែកខ្លះនៃភូមិ១៦) | - សង្កាត់បឹងកក់ទី២ (ភូមិ២៣)<br>- សង្កាត់បឹងសាឡាង (ភូមិ១០ ភូមិ១៤ និងផ្នែកខ្លះនៃភូមិ១៦)<br>- សង្កាត់ផ្សារដើមគរ (ភូមិ១ ភូមិ២ ភូមិ៣ ភូមិ៥ ភូមិ៦ និងភូមិ៧) |
| ៥ | **ខណ្ឌដង្កោ** | **តំបន់លឿង** | **តំបន់លឿងទុំ** | **តំបន់ក្រហម** |
| | | - សង្កាត់ពងទឹក<br>- សង្កាត់ព្រៃវែង<br>- សង្កាត់រលួស<br>- សង្កាត់ស្ពានថ្ម<br>- សង្កាត់ទៀន<br>- សង្កាត់សាក់សំពៅ<br>- សង្កាត់ជើងឯក<br>- សង្កាត់គងនយ<br>- សង្កាត់ព្រៃស<br>- សង្កាត់ដង្កោ (លើកលែងភូមិម័ល ភូមិសំបួរ និងភូមិថ្មី)<br>- សង្កាត់ព្រែកកំពឹស (លើកលែង ភូមិដំណាក់សង្កែ និងភូមិក្រាំងស្វាយ)<br>- សង្កាត់ក្រាំងពង្រ (លើកលែង ភូមិទឹកថ្លា និងភូមិព្រៃសំព័រ) | - សង្កាត់ដង្កោ (ភូមិម័ល ភូមិសំបួរ និងភូមិថ្មី)<br>- សង្កាត់ព្រែកកំពឹស (ភូមិដំណាក់សង្កែ និងភូមិក្រាំងស្វាយ)<br>- សង្កាត់ក្រាំងពង្រ (ភូមិទឹកថ្លា និងភូមិព្រៃសំព័រ) | -គ្មាន- |



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ: (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

| | | | | |
|---|---|---|---|---|
| | | **តំបន់លឿង** | **តំបន់លឿងទុំ** | **តំបន់ក្រហម** |
| ៦ | **ខណ្ឌមានជ័យ** | - សង្កាត់ស្ទឹងមានជ័យទី១ (លើកលែងផ្នែកខ្លះនៃភូមិទ្រា)<br>- សង្កាត់ស្ទឹងមានជ័យទី២ (លើកលែងភូមិដំណាក់ធំ និងផ្នែកខ្លះនៃភូមិដំណាក់ធំ១)<br>- សង្កាត់ស្ទឹងមានជ័យទី៣ (លើកលែងផ្នែកខ្លះនៃភូមិទ្រា៤ ផ្នែកខ្លះនៃភូមិដំណាក់ធំ២ ផ្នែកខ្លះនៃភូមិដំណាក់ធំ៣ និងផ្នែកខ្លះនៃភូមិដំណាក់ធំ៥)<br>- សង្កាត់ចាក់អង្រែលើ<br>- សង្កាត់ចាក់អង្រែក្រោម<br>- សង្កាត់បឹងទំពន់ទី១ (លើកលែងភូមិចំរើនផល ភូមិចំរើនផល១ ភូមិចំរើនផល២ ភូមិចំរើនផល៤ និងភូមិចំរើនផល៥)<br>- សង្កាត់បឹងទំពន់ទី២ (លើកលែងភូមិត្នោតជ្រុំ និង ភូមិត្នោតជ្រុំ២) | - សង្កាត់បឹងទំពន់ទី១ (ភូមិចំរើនផល ភូមិចំរើនផល១ ភូមិចំរើនផល២ និងភូមិចំរើនផល៤)<br>- សង្កាត់បឹងទំពន់ទី២ (ភូមិត្នោតជ្រុំ និងភូមិត្នោតជ្រុំ២)<br>- សង្កាត់ស្ទឹងមានជ័យទី២ (ភូមិដំណាក់ធំ ភូមិព្រែកទាល់ ភូមិព្រែកទាល់១ ផ្នែកខ្លះនៃភូមិដំណាក់ធំ១ ផ្នែកខ្លះនៃភូមិភ្នាត)<br>- សង្កាត់ស្ទឹងមានជ័យទី៣ (ផ្នែកខ្លះនៃភូមិដំណាក់ធំ២ និងផ្នែកខ្លះនៃភូមិដំណាក់ធំ៥) | - សង្កាត់ស្ទឹងមានជ័យទី១ (ផ្នែកខ្លះនៃភូមិទ្រា និងផ្នែកខ្លះនៃភូមិថ្មី)<br>- សង្កាត់ស្ទឹងមានជ័យទី២ (ភូមិដំណាក់ធំ៤ និងផ្នែកខ្លះនៃភូមិភ្នាត)<br>- សង្កាត់ស្ទឹងមានជ័យទី៣ (ផ្នែកខ្លះនៃភូមិទ្រា៤ ផ្នែកខ្លះនៃភូមិដំណាក់ធំ២, ផ្នែកខ្លះនៃភូមិដំណាក់ធំ៣ និងផ្នែកខ្លះនៃភូមិដំណាក់ធំ៥ ) |
| | | **តំបន់លឿង** | **តំបន់លឿងទុំ** | **តំបន់ក្រហម** |
| ៧ | **ខណ្ឌឫស្សីកែវ** | - សង្កាត់ស្វាយប៉ាក<br>- សង្កាត់ទួលសង្កែទី២<br>- សង្កាត់គីឡូម៉ែត្រលេខ៦<br>- សង្កាត់ឫស្សីកែវ (លើកលែងភូមិឃ្លាំងសាំង និងភូមិសាមគ្គី)<br>- សង្កាត់ច្រាំងចំរេះទី១ (លើកលែងភូមិ១ ភូមិ២ ភូមិ៣ និងផ្នែកខ្លះនៃភូមិ៤)<br>- សង្កាត់ច្រាំងចំរេះទី២ (លើកលែងភូមិក ភូមិឃ ផ្នែកខ្លះនៃភូមិខ២ និងផ្នែកខ្លះនៃភូមិខ១) | - សង្កាត់ទួលសង្កែទី១ (ភូមិផ្សារតូច ភូមិទួលសំពៅ ភូមិទួលគោក)<br>- សង្កាត់ឫស្សីកែវ (ភូមិឃ្លាំងសាំង និងភូមិ សាមគ្គី)<br>- សង្កាត់ច្រាំងចំរេះទី១ (ភូមិ១ ភូមិ២ ភូមិ៣ និងផ្នែកខ្លះនៃភូមិ៤)<br>- សង្កាត់ច្រាំងចំរេះទី២ (ភូមិក ភូមិឃ ផ្នែកខ្លះនៃភូមិខ២ និងផ្នែកខ្លះនៃភូមិខ១) | - សង្កាត់ទួលសង្កែទី១ (ភូមិទួលសង្កែ ភូមិចុងខ្សាច់ ភូមិបាក់ទូក) |
| | | **តំបន់លឿង** | **តំបន់លឿងទុំ** | **តំបន់ក្រហម** |
| ៨ | **ខណ្ឌសែនសុខ** | - សង្កាត់ភ្នំពេញថ្មី<br>- សង្កាត់ឃ្មួញ<br>- សង្កាត់ក្រាំងធ្នង់<br>- សង្កាត់ទឹកថ្លា<br>- សង្កាត់អូរបែកក្អម<br>- សង្កាត់គោកឃ្លាង | -គ្មាន- | -គ្មាន- |



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ: (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

| | | | | |
|---|---|---|---|---|
| ៩ | **ខណ្ឌពោធិ៍សែនជ័យ** | **តំបន់លឿង** | **តំបន់លឿងទុំ** | **តំបន់ក្រហម** |
| | | - សង្កាត់ត្រពាំងក្រសាំង<br>- សង្កាត់សំរោងក្រោម<br>- សង្កាត់កាកាបទី១ (លើកលែងភូមិតាងួន២)<br>- សង្កាត់កាកាបទី២<br>- សង្កាត់ចោមចៅទី២ (លើកលែងភូមិជ្រៃកោង និងភូមិថ្មគោលទី២)<br>- សង្កាត់ចោមចៅទី៣ (លើកលែងភូមិព្រៃទា១ និងភូមិព្រៃព្រីងខាងត្បូង២) | - សង្កាត់ចោមចៅទី១ (ភូមិចោមចៅ១ ភូមិត្រពាំងរំចេក និងភូមិគោកចំបក់)<br>- សង្កាត់ចោមចៅទី២ (ភូមិថ្មគោលទី២)<br>- សង្កាត់ចោមចៅទី៣ (ភូមិព្រៃទា១ និងភូមិព្រៃព្រីងខាងត្បូង២)<br>- សង្កាត់កាកាបទី១ (ភូមិតាងួន២) | - សង្កាត់ចោមចៅទី១ (ភូមិត្រពាំងថ្លឹង១ ភូមិត្រពាំងថ្លឹង២ ភូមិត្រពាំងថ្លឹង៣ ភូមិត្រពាំងថ្លឹង៤ និងភូមិទួលពង្រ)<br>- សង្កាត់ចោមចៅទី២ (ភូមិជ្រៃកោង) |
| ១០ | **ខណ្ឌជ្រោយចង្វារ** | **តំបន់លឿង** | **តំបន់លឿងទុំ** | **តំបន់ក្រហម** |
| | | - សង្កាត់ព្រែកតាសេក<br>- សង្កាត់ព្រែកលៀប<br>- សង្កាត់កោះដាច់<br>- សង្កាត់បាក់ខែង<br>- សង្កាត់ជ្រោយចង្វារ | -គ្មាន- | -គ្មាន- |
| ១១ | **ខណ្ឌព្រែកព្នៅ** | **តំបន់លឿង** | **តំបន់លឿងទុំ** | **តំបន់ក្រហម** |
| | | - សង្កាត់ពន្សាំង<br>- សង្កាត់ពញាពន់<br>- សង្កាត់សំរោង (លើកលែងផ្នែកខ្លះនៃភូមិគ្រួស)<br>- សង្កាត់ព្រែកព្នៅ (លើកលែងភូមិពោធិ៍មង្គល និងផ្នែកខ្លះនៃភូមិព្រែកព្នៅ)<br>- សង្កាត់គោករកា (លែកលែងផ្នែកខ្លះនៃភូមិភ្លូផ្អែម ផ្នែកខ្លះនៃភូមិពុទ្រា ផ្នែកខ្លះនៃភូមិត្រពាំងពោធិ៍ និងផ្នែកខ្លះនៃភូមិជំរៅ) | - សង្កាត់ព្រែកព្នៅ (ភូមិពោធិ៍មង្គល និងផ្នែកខ្លះនៃភូមិព្រែកព្នៅ)<br>- សង្កាត់សំរោង (ផ្នែកខ្លះនៃភូមិគ្រួស)<br>- សង្កាត់គោករកា (ផ្នែកខ្លះនៃភូមិភ្លូផ្អែម ផ្នែកខ្លះនៃភូមិពុទ្រា ផ្នែកខ្លះនៃភូមិត្រពាំងពោធិ៍ និងផ្នែកខ្លះនៃភូមិជំរៅ) | -គ្មាន- |
| ១២ | **ខណ្ឌច្បារអំពៅ** | **តំបន់លឿង** | **តំបន់លឿងទុំ** | **តំបន់ក្រហម** |
| | | - សង្កាត់វាលស្បូវ<br>- សង្កាត់ព្រែកឯង<br>- សង្កាត់ក្បាលកោះ<br>- សង្កាត់ព្រែកថ្មី<br>- សង្កាត់ព្រែកប្រា<br>- សង្កាត់និរោធ (លើកលែងផ្នែកខ្លះនៃភូមិឫស្សីស្រស់)<br>- សង្កាត់ច្បារអំពៅទី១ (លើកលែងផ្នែកខ្លះនៃភូមិព្រែក)<br>- សង្កាត់ច្បារអំពៅទី២ (លើកលែងផ្នែកខ្លះនៃភូមិដើមចាន់) | - សង្កាត់និរោធ (ផ្នែកខ្លះនៃភូមិឫស្សីស្រស់)<br>- សង្កាត់ច្បារអំពៅទី១ (ផ្នែកខ្លះនៃភូមិព្រែក) | - សង្កាត់ច្បារអំពៅទី២ (ផ្នែកខ្លះនៃភូមិដើមចាន់) |



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ: (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

| | | | | |
|---|---|---|---|---|
| ១៣ | **ខណ្ឌបឹងកេងកង** | **តំបន់លឿង** | **តំបន់លឿងទុំ** | **តំបន់ក្រហម** |
| | | - សង្កាត់បឹងកេងកងទី១<br>- សង្កាត់បឹងកេងកងទី២<br>- សង្កាត់បឹងកេងកងទី៣<br>- សង្កាត់ទួលស្វាយព្រៃទី១<br>- សង្កាត់ទួលស្វាយព្រៃទី២<br>- សង្កាត់អូឡាំពិក<br>- សង្កាត់ទំនប់ទឹក | -គ្មាន- | -គ្មាន- |
| ១៤ | **ខណ្ឌកំបូល** | **តំបន់លឿង** | **តំបន់លឿងទុំ** | **តំបន់ក្រហម** |
| | | - សង្កាត់ឪឡោក<br>- សង្កាត់ភ្លើងឆេះរទេះ<br>- សង្កាត់បឹងធំ<br>- សង្កាត់ប្រទះឡាង<br>- សង្កាត់ស្នោរ<br>- សង្កាត់កន្ទោក (លើកលែងផ្នែកខ្លះនៃភូមិត្រពាំងឈូក)<br>- សង្កាត់កំបូល (លើកលែងផ្នែកខ្លះនៃភូមិផ្សារកំបូល និងផ្នែកខ្លះនៃភូមិតាសេក) | - សង្កាត់កំបូល (ផ្នែកខ្លះនៃភូមិផ្សារកំបូល និងផ្នែកខ្លះនៃភូមិតាសេក)<br>- សង្កាត់កន្ទោក (ផ្នែកខ្លះនៃភូមិត្រពាំងឈូក) | -គ្មាន- |

ពាក្យ **"ផ្នែកខ្លះនៃ..."** គឺសំដៅលើទីតាំងភូមិសាស្ត្រដែលបានបង្ហាញជាក់ស្តែង នៅក្នុងផែនទីឧបសម្ព័ន្ធជូនភ្ជាប់សេចក្តីសម្រេចនេះ។

**ប្រការ៣ .-**

ក្នុងអំឡុងពេលនៃការអនុវត្តការបិទខ្ទប់ វិធានការដែលត្រូវអនុវត្តសម្រាប់ភូមិសាស្ត្រដែលត្រូវបានកំណត់ជា "**តំបន់ក្រហម**" មានដូចខាងក្រោម៖

**១**-បុគ្គលគ្រប់រូបត្រូវបានហាមឃាត់មិនឱ្យធ្វើដំណើរចេញពីលំនៅឋាន ឬ ទីសំណាក់បច្ចុប្បន្នរបស់ខ្លួន ដោយរួមទាំងការមិនអនុញ្ញាតឱ្យធ្វើសកម្មភាពកីឡានៅខាងក្រៅលំនៅឋាន ឬ ទីសំណាក់របស់ខ្លួន ប៉ុន្តែ ការធ្វើដំណើរចេញក្រៅពីលំនៅឋាន ឬ ទីសំណាក់បច្ចុប្បន្ន ឬ ការធ្វើដំណើរចេញ-ចូល **"តំបន់ក្រហម"** អាចត្រូវបានអនុញ្ញាតក្នុងករណីចាំបាច់ ដូចតទៅ៖

- ការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់
- ការធ្វើដំណើរទៅជួបមន្ត្រីសុខាភិបាលដើម្បីយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ឬ ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ នៅទីតាំងជិតបំផុតក្នុង **"តំបន់ក្រហម"** តាមការកំណត់ និងដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច
- ការធ្វើដំណើររបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលមានសមត្ថកិច្ចអនុវត្តវិធានការនានាក្នុងអំឡុងពេលបិទខ្ទប់ ដោយត្រូវភ្ជាប់ជាមួយនូវលិខិតបញ្ជាបេសកកម្ម
- ការធ្វើដំណើរដែលទាក់ទងនឹងសកម្មភាពចុះចែកជំនួយសង្គ្រោះបន្ទាន់ ដែលរៀបចំដោយអាជ្ញាធរមូលដ្ឋាន ដោយភ្ជាប់ជាមួយនូវអត្តសញ្ញាណប័ណ្ណ និងលិខិតបញ្ជាបេសកកម្ម ដែលចេញដោយរដ្ឋបាលរាជធានីភ្នំពេញ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ: (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

- ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកផ្នែកសុខាភិបាលទាំងរដ្ឋ និងឯកជនដោយរួមទាំងផ្នែកឱសថស្ថាន ដែលមានលិខិតអនុញ្ញាតចេញដោយក្រសួងសុខាភិបាល
- ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកនៃសេវាសង្គ្រោះបន្ទាន់ទាំងរដ្ឋ និងឯកជន ដែលមានលិខិតអនុញ្ញាតចេញដោយក្រសួងសុខាភិបាល
- ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិកនៃសេវាពន្លត់អគ្គិភ័យ
- ការធ្វើដំណើររបស់មន្ត្រី និងបុគ្គលិកនៃសេវាផ្គត់ផ្គង់អគ្គិសនី សេវាផ្គត់ផ្គង់ទឹកស្អាត និងសេវាផ្គត់ផ្គង់ស្បៀងរបស់រដ្ឋ ដោយត្រូវភ្ជាប់ជាមួយនូវលិខិតបញ្ជាបេសកកម្ម
- ការធ្វើដំណើររបស់មន្ត្រី ឬ បុគ្គលិកនៃសេវាប្រតិបត្តិការផ្នែកទូរគមនាគមន៍ ដោយមានលិខិតបញ្ជាបេសកកម្ម ឬ លិខិតអនុញ្ញាតធ្វើដំណើររបស់រដ្ឋបាលរាជធានីភ្នំពេញ
- ការធ្វើដំណើររបស់មន្ត្រីនិងបុគ្គលិក ដើម្បីចេញ-ចូលទីតាំងឃ្លាំងស្តុកទំនិញយុទ្ធសាស្ត្ររបស់រដ្ឋ ដោយត្រូវភ្ជាប់ជាមួយនូវលិខិតបញ្ជាបេសកកម្ម
- ការធ្វើដំណើររបស់បុគ្គលិកនៃទីតាំងផលិតនិងផ្គត់ផ្គង់មី ដោយមានលិខិតអនុញ្ញាតធ្វើដំណើររបស់រដ្ឋបាលរាជធានីភ្នំពេញ
- ការធ្វើដំណើររបស់បុគ្គលិកនៃទីតាំងផលិតនិងផ្គត់ផ្គង់អាល់កុលនិងអុកស៊ីហ្សែន ដោយមានលិខិតអនុញ្ញាតធ្វើដំណើររបស់រដ្ឋបាលរាជធានីភ្នំពេញ
- ការធ្វើដំណើររបស់បុគ្គលិកលក់ និងចែកចាយហ្គាសសម្រាប់ចម្អិនអាហារដោយមានលិខិតអនុញ្ញាតធ្វើដំណើររបស់រដ្ឋបាលរាជធានីភ្នំពេញ
- ការធ្វើដំណើររបស់បុគ្គលិកនៃសេវាប្រមូល និងដឹកជញ្ជូនសំរាម-សំណល់រឹង
- ការធ្វើដំណើរដើម្បីត្រឡប់ទៅលំនៅឋាន ឬ ទីសំណាក់របស់ខ្លួនវិញរបស់បុគ្គលដែលបានបញ្ចប់ការធ្វើចត្តាឡីស័ក និងអ្នកជំងឺចេញពីមន្ទីរពេទ្យ ឬ កន្លែងសម្រាកព្យាបាល នៅក្នុង ឬ ចេញពី ឬ ចូលក្នុង **"តំបន់ក្រហម"** ដោយមានការសម្របសម្រួលរបស់អាជ្ញាធរមានសមត្ថកិច្ច។

**២**-ផ្សារ ទីកន្លែងលក់ម្ហូបអាហារនិងគ្រឿងឧបភោគបរិភោគ ដោយរួមទាំងទីកន្លែងលក់និងសេពគ្រឿងស្រវឹងគ្រប់ប្រភេទ និងទីកន្លែងផ្តល់សេវាកម្មនានា ព្រមទាំងសកម្មភាពការងារ មុខរបរ និងអាជីវកម្មទាំងអស់នៅក្នុង **"តំបន់ក្រហម"** ត្រូវផ្អាកជាបណ្តោះអាសន្ន លើកលែងតែសកម្មភាពការងារ មុខរបរ និងអាជីវកម្ម ដូចខាងក្រោមនេះ ដែលត្រូវបានអនុញ្ញាតឱ្យដំណើរការជាធម្មតា៖

- សេវាពន្លត់អគ្គិភ័យ
- សេវាផ្គត់ផ្គង់អគ្គិសនី
- សេវាផ្គត់ផ្គង់ទឹកស្អាត
- សេវាប្រតិបត្តិការផ្នែកទូរគមនាគមន៍
- សេវាសង្គ្រោះបន្ទាន់ និងសេវាសុខាភិបាលទាំងរដ្ឋនិងឯកជន ដោយរួមទាំងឱសថស្ថាន
- អាជីវកម្មផលិតនិងផ្គត់ផ្គង់អាល់កុល និងអុកស៊ីហ្សែន
- អាជីវកម្មផលិតនិងផ្គត់ផ្គង់មី
- អាជីវកម្មលក់ហ្គាសសម្រាប់ចម្អិនអាហារ
- សេវាផ្គត់ផ្គង់ស្បៀងរបស់រដ្ឋ ឬ សម្របសម្រួលដោយរដ្ឋ និងជំនួយសង្គ្រោះបន្ទាន់
- សេវាផ្គត់ផ្គង់ឱសថ និងសម្ភារៈបរិក្ខារពេទ្យ និង
- សេវាប្រមូល និងដឹកជញ្ជូនសំរាម-សំណល់រឹង

**៣**-រាល់ការជួបជុំ ឬ ការប្រមូលផ្តុំមនុស្ស ដើម្បីសេពគ្រឿងស្រវឹងគ្រប់ប្រភេទ ត្រូវបានហាមឃាត់។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ: (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

**ប្រការ៤** ..

ក្នុងអំឡុងពេលនៃការអនុវត្តការបិទខ្ទប់ វិធានការដែលត្រូវអនុវត្តសម្រាប់ភូមិសាស្ត្រដែលត្រូវបានកំណត់ជា **"តំបន់លឿងទុំ"** មានដូចខាងក្រោម៖

១-បុគ្គលគ្រប់រូបត្រូវបានហាមឃាត់មិនឱ្យធ្វើដំណើរ ចេញពីលំនៅឋាន ឬ ទីសំណាក់បច្ចុប្បន្នរបស់ខ្លួន ប៉ុន្តែ ការធ្វើដំណើរចេញក្រៅពីលំនៅឋាន ឬ ទីសំណាក់បច្ចុប្បន្ន អាចត្រូវបានអនុញ្ញាតក្នុងករណីចាំបាច់ ដូចតទៅ៖

- ការធ្វើដំណើរទៅប្រកបមុខរបរ ឬ អាជីវកម្ម ឬ បំពេញការងារក្នុងវិស័យឯកជន ដែលត្រូវបានអនុញ្ញាត ដោយ**ចំណុចទី២ នៃប្រការ៤** នៃសេចក្ដីសម្រេចនេះ ដោយត្រូវមានលិខិតអនុញ្ញាតធ្វើដំណើរពីរដ្ឋបាលរាជធានីភ្នំពេញ អមដោយឯកសារបញ្ជាក់អត្តសញ្ញាណ និងលិខិតបញ្ជាក់ការងារដែលមានកំណត់ច្បាស់លាស់ពីឈ្មោះ មុខងារ និងប្រភេទអាជីវកម្មចេញដោយទីកន្លែងអាជីវកម្មពាក់ព័ន្ធ
- ការធ្វើដំណើរទៅបំពេញការងារក្នុងក្រសួង-ស្ថាប័នរដ្ឋ ត្រូវមានលិខិតបញ្ជាបេសកកម្មរបស់ក្រសួង-ស្ថាប័នសាមី ដោយភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់អត្តសញ្ញាណ
- ការធ្វើដំណើរទៅកាន់ទីកន្លែងលក់ម្ហូបអាហារ ឬ គ្រឿងឧបភោគបរិភោគ ឱសថស្ថាន និងទីកន្លែងលក់សម្ភារៈប្រើប្រាស់ចាំបាច់ប្រចាំថ្ងៃ ដែលអនុញ្ញាតឱ្យបើកដំណើរការដោយអាជ្ញាធរមានសមត្ថកិច្ច។ ការធ្វើដំណើរក្នុងគោលបំណងនេះ អាចធ្វើឡើងដោយសមាជិកយ៉ាងច្រើន **២ (ពីរ) នាក់** ក្នុងមួយលំនៅឋាន ឬ ទីសំណាក់ ដោយមិនឱ្យលើសពី **៣ (បី) ដង ក្នុងមួយសប្ដាហ៍** និងនៅទីតាំងដែលជិតបំផុតក្នុងរង្វង់ភូមិសាស្ត្រខណ្ឌដែលខ្លួនរស់នៅ ដោយត្រូវយកតាមខ្លួននូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬ ប័ណ្ណសម្គាល់ខ្លួន
- ការធ្វើដំណើរទៅមន្ទីរពេទ្យ មណ្ឌលសុខភាព សម្ភព ឬ ទីកន្លែងព្យាបាល ដោយមូលហេតុសុខភាពបន្ទាន់នៅក្នុងរង្វង់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់។ ការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់នេះ ចេញក្រៅ ឬ ចូលក្នុងរង្វង់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ អាចធ្វើទៅបានដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់ ដោយកំណត់ចំនួនមនុស្សមិនឱ្យលើសពី **៤ (បួន) នាក់** សម្រាប់ករណីនីមួយៗ ប៉ុន្តែ ត្រូវអនុវត្តដាច់ខាតនូវកាតព្វកិច្ចទាក់ទងនឹងវិធានការសុវត្ថិភាពផ្នែកសុខាភិបាល
- ការធ្វើដំណើរទៅជួបមន្ត្រីសុខាភិបាល ដើម្បីយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ឬ ចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ នៅទីតាំងជិតបំផុតក្នុង **"តំបន់លឿងទុំ"** តាមការកំណត់ និងដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច
- ការធ្វើដំណើរដើម្បីចូលរួមក្នុងសកម្មភាពដែលបម្រើប្រយោជន៍សាធារណៈ ឬ គោលបំណងចាំបាច់ផ្សេងទៀត តាមការស្នើសុំ ឬ តាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់
- ការធ្វើសកម្មភាពកីឡាជាលក្ខណៈបុគ្គលក្នុងរង្វង់ភូមិសាស្ត្រភូមិដែលខ្លួនរស់នៅ ដោយចៀសវាងការជួបជុំមនុស្សលើសពី **២ (ពីរ) នាក់**
- ការធ្វើដំណើររបស់ជនបរទេសដែលជាមន្ត្រីការទូត មន្ត្រីបុគ្គលិកនៃស្ថានតំណាងបរទេស ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងដែលជាមន្ត្រីរបស់អង្គការហិរញ្ញវត្ថុអន្តរជាតិ ដោយមានភ្ជាប់ជាមួយ នូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងការងារ និងអាចអមដោយអ្នកបើកបររថយន្តជាជនជាតិខ្មែរ
- ការធ្វើដំណើររបស់អ្នកសារព័ត៌មាន ដោយមានភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អំពីអត្តសញ្ញាណនិងការងារ ព្រមទាំងមានលិខិតអនុញ្ញាតសម្រាប់ការធ្វើដំណើរពីក្រសួងព័ត៌មាន
- ការធ្វើដំណើរដើម្បីត្រឡប់ទៅលំនៅឋាន ឬ ទីសំណាក់របស់ខ្លួនវិញរបស់បុគ្គលដែលបានបញ្ចប់ការធ្វើចត្តាឡីស័ក និងអ្នកជំងឺចេញពីមន្ទីរពេទ្យ ឬ កន្លែងសម្រាកព្យាបាល នៅក្នុង ឬ ចេញពី ឬ ចូលក្នុង **"តំបន់លឿងទុំ"** ដោយមានការសម្របសម្រួលរបស់អាជ្ញាធរមានសមត្ថកិច្ច
- ការធ្វើដំណើរដោយមូលហេតុចាំបាច់និងបន្ទាន់ផ្សេងទៀត ដោយមានការអនុញ្ញាតជាមុនពីអាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់។

ការធ្វើដំណើរដូចបានរៀបរាប់ខាងលើនេះ ត្រូវបានអនុញ្ញាតនៅក្នុង **"តំបន់លឿងទុំ"** និងឆ្លងចេញ-ចូល **"តំបន់លឿង"** ប៉ុន្តែ ការធ្វើដំណើរចេញពី **"តំបន់លឿងទុំ"** ឆ្លងកាត់ **"តំបន់ក្រហម"** ឬ ទៅក្រៅភូមិសាស្ត្ររាជធានីភ្នំពេញ ត្រូវបានអនុញ្ញាតតែក្នុងករណីដែលមានចែងក្នុង**ចំណុចទី១ នៃប្រការ៣** នៃសេចក្ដីសម្រេចនេះប៉ុណ្ណោះ។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ: (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

២-ត្រូវបានហាមឃាត់រាល់សកម្មភាពការងារ មុខរបរ ឬ អាជីវកម្មទាំងអស់ ដែលមិនមែនជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ប៉ុន្តែ សកម្មភាពការងារ មុខរបរ ឬ អាជីវកម្ម អាចត្រូវបានអនុញ្ញាតក្នុងករណីចាំបាច់ ដូចតទៅ៖

- សកម្មភាពការងាររបស់ស្ថាប័នសាធារណៈ ដើម្បីធានានិរន្តរភាពការងាររបស់ស្ថាប័ន។ ការធ្វើដំណើររបស់មន្ត្រីនៃស្ថាប័នសាធារណៈសម្រាប់គោលបំណងនេះ ត្រូវភ្ជាប់ជាមួយនូវឯកសារបញ្ជាក់អត្តសញ្ញាណ និងលិខិតបញ្ជាបេសកកម្មដែលចេញដោយស្ថាប័នសាមី
- សកម្មភាពការងាររបស់រដ្ឋបាលរាជធានីភ្នំពេញ រដ្ឋបាលខណ្ឌទាំង១៤ អាជ្ញាធរមូលដ្ឋានគ្រប់លំដាប់ថ្នាក់ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ព្រមទាំងមន្ត្រីនិងបុគ្គលិកសុខាភិបាល ត្រូវដំណើរការស្របតាមការចាំបាច់ និងតាមការកំណត់របស់ប្រធានស្ថាប័ននីមួយៗ
- រោងចក្រ សហគ្រាស សិប្បកម្ម ឬ ទីកន្លែងផលិតឱសថ និងសម្ភារៈបរិក្ខារពេទ្យ រួមទាំងម៉ាស អាល់កុល និងអុកស៊ីហ្សែន
- រោងចក្រ សហគ្រាស សិប្បកម្ម ឬ ទីកន្លែងផលិតម្ហូបអាហារនិងគ្រឿងឧបភោគបរិភោគ ដោយរួមទាំងទីសត្តឃាត ដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ
- សកម្មភាពការងារដែលពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ តាមការកំណត់របស់ស្ថាប័ននីមួយៗ ជាអាទិ៍ សេវាពន្លត់អគ្គិភ័យ សេវាផ្គត់ផ្គង់អគ្គិសនី សេវាផ្គត់ផ្គង់ទឹកស្អាត សេវាកំពង់ផែ សេវាប្រមូល និងដឹកជញ្ជូនសំរាម-សំណល់រឹង ជាដើម។ ការធ្វើដំណើររបស់មន្ត្រី ឬ បុគ្គលិកដើម្បីបម្រើឱ្យសេវាទាំងនេះ ត្រូវភ្ជាប់ជាមួយឯកសារបញ្ជាក់អត្តសញ្ញាណ និងលិខិតបញ្ជាបេសកកម្មដែលចេញដោយស្ថាប័នសាមី
- រាល់សកម្មភាពការងារ មុខរបរ ឬ អាជីវកម្ម ដែលដំណើរការតាមរយៈប្រព័ន្ធអនឡាញ ដោយត្រូវកាត់បន្ថយចំនួនអ្នកធ្វើការឱ្យមកនៅត្រឹមកម្រិតអប្បបរមាមិនឱ្យលើសពី **២%** និងត្រូវអនុវត្តគោលការណ៍អាហារថ្ងៃត្រង់នៅហ្នឹងកន្លែងបំពេញការងារ
- ការផ្គត់ផ្គង់ទំនិញដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ជាអាទិ៍ ផ្សារលក់ដុំ ផ្សារឬទីតាំងលក់ដូរគ្រឿងឧបភោគបរិភោគដែលមានសណ្តាប់ធ្នាប់ ផ្សារម៉ាត និងភោជនីយដ្ឋាន-អាហារដ្ឋានដែលលក់ជាអាហារវេចខ្ចប់ ស្ថានីយ៍ប្រេងឥន្ធនៈ-ហ្គាស ទីតាំងលក់ហ្គាស ឬ ទីតាំងផ្គត់ផ្គង់ទំនិញដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃផ្សេងទៀតដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។ ចំពោះផ្សារ ឬ ទីតាំងលក់ដូរគ្រឿងឧបភោគបរិភោគ ភោជនីយដ្ឋាន-អាហារដ្ឋាន រដ្ឋបាលខណ្ឌនីមួយៗ ត្រូវធ្វើការត្រួតពិនិត្យ និងសម្រេចអនុញ្ញាតទៅតាមការជាក់ស្តែង ដោយផ្អែកទៅលើតម្រូវការចាំបាច់នៅក្នុងភូមិសាស្ត្ររបស់ខ្លួន
- ការផ្គត់ផ្គង់សេវាដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ ជាអាទិ៍ សេវាសង្គ្រោះបន្ទាន់ និងសេវាសុខាភិបាលទាំងរដ្ឋ និងឯកជន ឱសថស្ថាន សេវាប្រៃសណីយ៍-ទូរគមនាគមន៍ សេវាធនាគារ និងហិរញ្ញវត្ថុ និងសេវាដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃផ្សេងទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ប៉ុន្តែ ត្រូវកាត់បន្ថយចំនួនបុគ្គលិកបម្រើការឱ្យមកនៅត្រឹមកម្រិតអប្បបរមាមិនឱ្យលើសពី **២%** និងត្រូវអនុវត្តគោលការណ៍អាហារថ្ងៃត្រង់នៅហ្នឹងកន្លែងបំពេញការងារ លើកលែងតែសេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល និងឱសថស្ថាន ដែលត្រូវដំណើរការជាធម្មតា
- សេវាកម្មសណ្ឋាគារ និងផ្ទះសំណាក់ ប៉ុន្តែ ត្រូវកាត់បន្ថយចំនួនបុគ្គលិកបម្រើការឱ្យមកនៅត្រឹមកម្រិតអប្បបរមាមិនឱ្យលើសពី **២%** និងត្រូវអនុវត្តគោលការណ៍អាហារ និងការស្នាក់នៅ នៅហ្នឹងកន្លែងបំពេញការងារ លើកលែងតែសណ្ឋាគារដែលបម្រើឱ្យការធ្វើចត្តាឡីស័ក ដែលចំនួនបុគ្គលិកអប្បបរមា និងពេលម៉ោងធ្វើការរបស់បុគ្គលិក ត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ចដែលអនុវត្តវិធានការបិទខ្ទប់
- សេវាកម្មដឹកជញ្ជូនម្ហូបអាហារឬគ្រឿងឧបភោគបរិភោគ ដើម្បីបម្រើឱ្យភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់។ សកម្មភាពនៃការដឹកជញ្ជូននេះ មិនត្រូវបានអនុញ្ញាតឱ្យមានការដឹកជញ្ជូនមនុស្សឡើយ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទៈ (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារៈ (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

- ការដឹកជញ្ជូនទំនិញយុទ្ធសាស្ត្ររបស់រដ្ឋ
- សេវាកម្មដឹកជញ្ជូនទំនិញទូទៅចេញ-ចូល ឬ ឆ្លងកាត់ភូមិសាស្ត្រដែលត្រូវបានបិទខ្ទប់ ដើម្បីបម្រើឱ្យវិស័យសង្គម-សេដ្ឋកិច្ចនៃប្រទេស។ សកម្មភាពនៃការដឹកជញ្ជូននេះ មិនត្រូវបានអនុញ្ញាតឱ្យមានការដឹកជញ្ជូនមនុស្សឡើយ
- ចំពោះការគ្រប់គ្រង និងថែរក្សាឃ្លាំងស្តុកទំនិញ ឬ គ្រឿងឧបភោគបរិភោគ ត្រូវបានអនុញ្ញាតឱ្យមានបុគ្គលិកប្រចាំការក្នុងចំនួនអប្បបរមា និងត្រូវអនុវត្តគោលការណ៍អាហារ និងការស្នាក់នៅ នៅហ្នឹងកន្លែងបំពេញការងារ
- សកម្មភាពការងារ មុខរបរ ឬ អាជីវកម្មចាំបាច់ដទៃទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

៣-ត្រូវហាមឃាត់រាល់ការជួបជុំ ឬ ការប្រមូលផ្តុំមនុស្ស លើកលែងតែក្នុងករណីចាំបាច់ ដូចតទៅៈ
- ការជួបជុំក្នុងចំណោមសមាជិកគ្រួសារដែលរស់នៅក្នុងលំនៅឋាន ឬ ទីសំណាក់ជាមួយគ្នា
- ការរៀបចំពិធីបុណ្យសព ដោយគោរពតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច
- ការប្រមូលផ្តុំមនុស្ស និងការជួបជុំរបស់បុគ្គលិកសុខាភិបាល ដើម្បីអនុវត្តវិធានការសុខាភិបាល ជាអាទិ៍ ការយកវត្ថុសំណាកមកវិភាគរកមេរោគកូវីដ-១៩ និងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ និងការជួបជុំរបស់បុគ្គលិកសុខាភិបាលដែលបំពេញការងារសង្គ្រោះបន្ទាន់ផ្សេងទៀត
- ការជួបជុំរបស់អាជ្ញាធរមានសមត្ថកិច្ច កម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់លំដាប់ថ្នាក់ ក្នុងការបំពេញការងារថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ។

រាល់ការជួបជុំ ឬ ការប្រមូលផ្តុំមនុស្សដើម្បីសេពគ្រឿងស្រវឹងគ្រប់ប្រភេទ ត្រូវបានហាមឃាត់។

៤-ត្រូវបានអនុវត្តបម្រាមគោចរនៅ **"តំបន់លឿងទុំ"** ដោយផ្អាកជាបណ្តោះអាសន្ននូវរាល់ការធ្វើចរាចរណ៍ និងរាល់សកម្មភាពការងារ មុខរបរ ឬ អាជីវកម្ម **នៅចន្លោះម៉ោង ២០ (ម្ភៃ) ដល់ម៉ោង ៣ (បី)** លើកលែងតែក្នុងករណី ដូចតទៅៈ

- ការធ្វើដំណើររបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ ដែលមានសមត្ថកិច្ចអនុវត្តវិធានការនានា ក្នុងអំឡុងពេលបិទខ្ទប់ ដោយត្រូវភ្ជាប់ជាមួយនូវលិខិតបញ្ជាបេសកកម្ម
- ការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់
- មូលហេតុចាំបាច់និងបន្ទាន់ក្នុងគ្រួសារ
- ការដឹកជញ្ជូនទំនិញ
- ការដឹកជញ្ជូនទំនិញយុទ្ធសាស្ត្ររបស់រដ្ឋ
- ទីតាំងផលិតនិងផ្គត់ផ្គង់អាល់កុល និងអុកស៊ីហ្សែន
- ទីតាំងផលិតនិងផ្គត់ផ្គង់មី
- ការបំពេញកាតព្វកិច្ចដែលបម្រើផលប្រយោជន៍សាធារណៈ
- សេវាសង្គ្រោះបន្ទាន់ និងសេវាសុខាភិបាល ទាំងរដ្ឋ និងឯកជន
- ឱសថស្ថាន
- សេវាពន្លត់អគ្គិភ័យ
- សេវាផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាត
- សេវាបម្រើប្រតិបត្តិការផ្នែកទូរគមនាគមន៍
- ស្ថានីយ៍ប្រេងឥន្ធនៈ-ហ្គាស
- សេវាសណ្ឋាគារ និងផ្ទះសំណាក់
- ករណីចាំបាច់ និងសេវាសាធារណៈចាំបាច់ដទៃទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ: (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

**៥**-ផ្សារ ទីកន្លែងលក់ដូរគ្រឿងឧបភោគបរិភោគ និងភោជនីយដ្ឋាន-អាហារដ្ឋាន ត្រូវលក់ដូរជាលក្ខណៈវេចខ្ចប់ ហើយរដ្ឋបាលខណ្ឌទាំង១៤ និងមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ ត្រូវរឹតបន្តឹង និងត្រួតពិនិត្យនៅតាមទីកន្លែងទាំងនោះ និងត្រូវហាមឃាត់មិនឱ្យបើកដំណើរការចំពោះទីតាំងណាដែលមិនរៀបរយ ឬ មានហានិភ័យខ្ពស់ក្នុងការចម្លង និងឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។

**៦**-រដ្ឋបាលខណ្ឌទាំង១៤ ត្រូវអនុវត្តការហាមឃាត់ ឬ ផ្អាកជាដាច់ខាតនូវរាល់ទីតាំងសកម្មភាពការងារ មុខរបរ ឬ អាជីវកម្ម ដែលត្រូវបានអនុញ្ញាតស្របតាម**ចំណុចទី២ នៃប្រការ៤** នៃសេចក្តីសម្រេចនេះ នៅពេលដែលទីកន្លែងនៃសកម្មភាពការងារ មុខរបរ ឬ អាជីវកម្មនោះ ជាពិសេសផ្សារនិងទីកន្លែងលក់ដូរគ្រឿងឧបភោគបរិភោគ និងភោជនីយដ្ឋាន-អាហារដ្ឋាន ត្រូវបានរកឃើញ ឬ មានការសង្ស័យថា មានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ លើកលែងតែចំពោះទីតាំងសកម្មភាពការងារដែលទាក់ទងនឹងសេវាពន្លត់អគ្គិភ័យ សេវាផ្គត់ផ្គង់អគ្គិសនី សេវាផ្គត់ផ្គង់ទឹកស្អាត សេវាបម្រើប្រតិបត្តិការផ្នែកទូរគមនាគមន៍ សេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល ឱសថស្ថាន ទីតាំងផលិត និងផ្គត់ផ្គង់អាល់កុល និងអុកស៊ីហ្សែន ទីតាំងផលិតនិងផ្គត់ផ្គង់មី ទីតាំងលក់ហ្គាសសម្រាប់ចម្អិនអាហារ និងទីតាំងឃ្លាំងស្តុកទំនិញយុទ្ធសាស្ត្ររបស់រដ្ឋ ដែលត្រូវបានអនុញ្ញាតឱ្យដំណើរការជាធម្មតា បន្ទាប់ពីអាជ្ញាធរមានសមត្ថកិច្ចបានចាត់វិធានការផ្នែកសុខាភិបាល ក្នុងការកំណត់អ្នកពាក់ព័ន្ធ ដែលត្រូវយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩ និងធ្វើចត្តាឡីស័ករួចរាល់។ រាល់ទីតាំងនៃសេវាកម្មដែលត្រូវបានលើកលែង និងអនុញ្ញាតឱ្យបើកដំណើរការនេះ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានការសុខាភិបាលរួមមាន ការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ និងការវាស់កម្តៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**ប្រការ៥** ..

ក្នុងអំឡុងពេលនៃការដាក់ចេញវិធានការរដ្ឋបាល សម្រាប់ភូមិសាស្ត្រដែលត្រូវបានកំណត់ជា **"តំបន់លឿង"** ការធ្វើដំណើរ សកម្មភាពការងារ មុខរបរ ឬ អាជីវកម្ម និងសកម្មភាពនៃការជួបជុំ ឬ ប្រមូលផ្តុំមនុស្ស ត្រូវបានអនុញ្ញាត ហាមឃាត់ ឬ រឹតត្បិត ដូចខាងក្រោមៈ

**១**-ការធ្វើចរាចរណ៍គ្រប់ប្រភេទនៅក្នុង **"តំបន់លឿង"** ត្រូវបានអនុញ្ញាតឱ្យប្រព្រឹត្តទៅជាធម្មតា។ ការធ្វើដំណើរចេញពី **"តំបន់លឿង"** ឆ្លងកាត់ **"តំបន់ក្រហម"** និង **"តំបន់លឿងទុំ"** ត្រូវបានអនុញ្ញាតតែក្នុងករណីដែលមានចែងក្នុង **ចំណុចទី១ នៃប្រការ៣ និងចំណុចទី១ នៃប្រការ៤** នៃសេចក្តីសម្រេចនេះ។ ដោយឡែក ការចេញទៅក្រៅភូមិសាស្ត្ររាជធានីភ្នំពេញ ត្រូវអនុវត្តតាមសេចក្តីណែនាំលេខ ០៣ សណន ចុះថ្ងៃទី៤ ខែឧសភា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការពង្រឹងការអនុវត្តវិធានការចាំបាច់មួយចំនួន ដើម្បីទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ បន្ទាប់ពីរាជរដ្ឋាភិបាលបានសម្រេចបញ្ចប់ការបិទខ្ទប់ភូមិសាស្ត្ររាជធានីភ្នំពេញ និងក្រុងតាខ្មៅនៃខេត្តកណ្តាល។

**២**-សកម្មភាពការងារ មុខរបរ និងអាជីវកម្មគ្រប់ប្រភេទនៅក្នុង **"តំបន់លឿង"** ត្រូវបានអនុញ្ញាតឱ្យបើកដំណើរការជាធម្មតា លើកលែងតែសាលារៀន រួមទាំងសាលាបណ្តុះបណ្តាលវិជ្ជាជីវៈទាំងរដ្ឋ និងឯកជន អាជីវកម្មក្លឹបកម្សាន្តគ្រប់ប្រភេទ ជាអាទិ៍ ខារ៉ាអូខេ រង្គសាល ឌីស្កូតែក និងបៀហ្គាឌិន រមណីយដ្ឋាន និងសួនកម្សាន្តនានា អាជីវកម្មម៉ាស្សា ហាងលក់និងសេពគ្រឿងស្រវឹងគ្រប់ប្រភេទ រោងភាពយន្ត រោងសម្តែងសិល្បៈ សារមន្ទីរ ក្លឹបហាត់ប្រាណ និងមជ្ឈមណ្ឌលកីឡា។ **រដ្ឋបាលរាជធានីភ្នំពេញ** នឹងពិនិត្យសម្រេច ហាមឃាត់សកម្មភាពការងារ មុខរបរ និងអាជីវកម្មផ្សេងទៀត ដោយយោងតាមតម្រូវការចាំបាច់ក្នុងការប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។ សកម្មភាពការងារ មុខរបរ និងអាជីវកម្មដែលបើកដំណើរការនៅក្នុង **"តំបន់លឿង"** ត្រូវអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាលឱ្យបានម៉ឺងម៉ាត់ ជាអាទិ៍ កាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពបុគ្គល និងត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ ការវាស់កម្តៅ និងការអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាលផ្សេងទៀត។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ: (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

**៣**-ការជួបជុំ ឬ ការប្រមូលផ្តុំមនុស្សជាលក្ខណៈឯកជនដែលមានលក្ខណៈកុះករកកកុញ ឬ ដែលមានមនុស្សចូលរួមលើសពី **១០ (ដប់) នាក់** ត្រូវបានហាមឃាត់ លើកលែងតែការជួបជុំក្នុងចំណោមសមាជិកគ្រួសារ ដែលរស់នៅក្នុងលំនៅឋាន ឬ ទីសំណាក់ជាមួយគ្នា ការរៀបចំពិធីបុណ្យសពដោយគោរពតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច ការជួបជុំរបស់ស្ថាប័នសាធារណៈ ការប្រមូលផ្តុំមនុស្ស និងការជួបជុំរបស់បុគ្គលិកសុខាភិបាលដើម្បីអនុវត្តវិធានការសុខាភិបាល ជាអាទិ៍ ការយកវត្ថុសំណាកមកវិភាគរកមេរោគកូវីដ-១៩ និងការចាក់វ៉ាក់សាំងការពារជំងឺកូវីដ-១៩ ការជួបជុំរបស់បុគ្គលិកសុខាភិបាលដែលបំពេញការងារសង្គ្រោះបន្ទាន់ផ្សេងទៀត និងការជួបជុំរបស់អាជ្ញាធរមានសមត្ថកិច្ច និងកម្លាំងគណៈបញ្ជាការឯកភាពរដ្ឋបាលគ្រប់លំដាប់ថ្នាក់ក្នុងការបំពេញការងារថែរក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងរបៀបរៀបរយសាធារណៈ, ការជួបជុំមនុស្សក្នុងអំឡុងពេលនៃកិច្ចនីតិវិធីរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬ របស់សាលាជម្រះក្តី និងការជួបជុំមនុស្សដែលមានភាពចាំបាច់សម្រាប់បម្រើផលប្រយោជន៍សាធារណៈ ឬ ក្នុងគោលបំណងផ្សេងទៀតតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ច។ ការហាមឃាត់ខាងលើនេះ មិនអនុវត្តចំពោះការជួបជុំ ឬ ការប្រមូលផ្តុំមនុស្ស ដើម្បីបំពេញការងារបម្រើឱ្យសកម្មភាពមុខរបរ ឬ អាជីវកម្មដែលត្រូវបានអនុញ្ញាតនៅក្នុង **"តំបន់លឿង"** ឡើយ។ រាល់សកម្មភាពនៃការជួបជុំ ឬ ការប្រមូលផ្តុំមនុស្ស ត្រូវអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាលឱ្យបានម៉ឺងម៉ាត់ ជាអាទិ៍ កាតព្វកិច្ចពាក់ម៉ាស និងកាតព្វកិច្ចរក្សាគម្លាតសុវត្ថិភាពបុគ្គល និងត្រូវប្រកាន់ខ្ជាប់នូវការធ្វើអនាម័យដើម្បីសម្លាប់មេរោគ ការវាស់កម្តៅ និងការអនុវត្តវិធានការសុវត្ថិភាពផ្នែកសុខាភិបាលផ្សេងទៀត។

**៤**-រាល់ការជួបជុំ ឬ ការប្រមូលផ្តុំមនុស្សដើម្បីសេពគ្រឿងស្រវឹងគ្រប់ប្រភេទ ត្រូវបានហាមឃាត់ លើកលែងក្នុងលំនៅឋាន ឬ ទីសំណាក់ជាមួយគ្នា។

**៥**-ត្រូវបានអនុវត្តបម្រាមគោចរនៅ **"តំបន់លឿង"** ដោយផ្អាកជាបណ្តោះអាសន្ននូវរាល់ការធ្វើចរាចរណ៍ និងរាល់សកម្មភាព ការងារ មុខរបរ ឬ អាជីវកម្ម **នៅចន្លោះម៉ោង ២០ (ម្ភៃ) ដល់ម៉ោង ៣ (បី)** លើកលែងតែក្នុងករណី ដូចតទៅ៖

- ការធ្វើដំណើររបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទដែលមានសមត្ថកិច្ចអនុវត្តវិធានការនានាក្នុងអំឡុងពេលបិទខ្ទប់ ដោយត្រូវភ្ជាប់ជាមួយនូវលិខិតបញ្ជាបេសកកម្ម
- ការធ្វើដំណើរដោយមូលហេតុសុខភាពបន្ទាន់
- មូលហេតុចាំបាច់និងបន្ទាន់ក្នុងគ្រួសារ
- ការដឹកជញ្ជូនទំនិញ
- ការដឹកជញ្ជូនទំនិញយុទ្ធសាស្ត្ររបស់រដ្ឋ
- ទីតាំងផលិតនិងផ្គត់ផ្គង់អាល់កុល និងអុកស៊ីហ្សែន
- ទីតាំងផលិតនិងផ្គត់ផ្គង់មី
- ការបំពេញកាតព្វកិច្ចដែលបម្រើផលប្រយោជន៍សាធារណៈ
- សេវាសង្គ្រោះបន្ទាន់ និងសេវាសុខាភិបាល ទាំងរដ្ឋ និងឯកជន
- ឱសថស្ថាន
- សេវាពន្លត់អគ្គិភ័យ
- សេវាផ្គត់ផ្គង់អគ្គិសនី និងទឹកស្អាត
- សេវាបម្រើប្រតិបត្តិការផ្នែកទូរគមនាគមន៍
- ស្ថានីយ៍ប្រេងឥន្ធនៈ-ហ្គាស
- សេវាសណ្ឋាគារ និងផ្ទះសំណាក់
- ករណីចាំបាច់ និងសេវាសាធារណៈចាំបាច់ដទៃទៀត ដោយមានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច។

**៦**-ផ្សារ ទីកន្លែងលក់ដូរគ្រឿងឧបភោគបរិភោគ និងភោជនីយដ្ឋាន-អាហារដ្ឋាន ត្រូវលក់ដូរជាលក្ខណៈវេចខ្ចប់ ហើយរដ្ឋបាលខណ្ឌទាំង១៤ និងមន្ទីរ-អង្គភាពជំនាញពាក់ព័ន្ធ ត្រូវរឹតបន្តឹង និងត្រួតពិនិត្យនៅតាមទីកន្លែងទាំងនោះ និងត្រូវហាមឃាត់មិនឱ្យបើកដំណើរការចំពោះទីតាំងណាដែលមិនរៀបរយ ឬ មានហានិភ័យខ្ពស់ក្នុងការចម្លង និងឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ។



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ: (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

**៧**-រដ្ឋបាលខណ្ឌទាំង១៤ ត្រូវអនុវត្តការហាមឃាត់ ឬ ផ្អាកជាដាច់ខាតនូវរាល់ទីតាំងសកម្មភាពការងារ មុខរបរ ឬ អាជីវកម្ម ដែលត្រូវបានអនុញ្ញាតស្របតាម**ចំណុចទី២ នៃប្រការ៥** នៃសេចក្តីសម្រេចនេះ នៅពេលដែលទីកន្លែងនៃសកម្មភាពការងារ មុខរបរ ឬ អាជីវកម្មនោះ ជាពិសេសផ្សារនិងទីកន្លែងលក់ដូរគ្រឿងឧបភោគបរិភោគ និងភោជនីយដ្ឋាន-អាហារដ្ឋាន ត្រូវបានរកឃើញ ឬ មានការសង្ស័យថាមានការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ លើកលែងតែចំពោះទីតាំងសកម្មភាពការងារដែលទាក់ទងនឹងសេវាពន្លត់អគ្គិភ័យ សេវាផ្គត់ផ្គង់អគ្គិសនី សេវាផ្គត់ផ្គង់ទឹកស្អាត សេវាបម្រើប្រតិបត្តិការផ្នែកទូរគមនាគមន៍ សេវាសង្គ្រោះបន្ទាន់ សេវាសុខាភិបាល ឱសថស្ថាន ទីតាំងផលិត និងផ្គត់ផ្គង់អាល់កុល និងអុកស៊ីហ្សែន ទីតាំងផលិតនិងផ្គត់ផ្គង់មី ទីតាំងលក់ហ្គាសសម្រាប់ចម្អិនអាហារ និងទីតាំងឃ្លាំងស្តុកទំនិញយុទ្ធសាស្ត្ររបស់រដ្ឋ ដែលត្រូវបានអនុញ្ញាតឱ្យដំណើរការជាធម្មតា បន្ទាប់ពីអាជ្ញាធរមានសមត្ថកិច្ចបានចាត់វិធានការផ្នែកសុខាភិបាល ក្នុងការកំណត់អ្នកពាក់ព័ន្ធដែលត្រូវយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩ និងធ្វើចត្តាឡីស័ករួចរាល់។ រាល់ទីតាំងនៃសេវាកម្មដែលត្រូវបានលើកលែង និងអនុញ្ញាតឱ្យបើកដំណើរការនេះ ត្រូវអនុវត្តឱ្យបានម៉ឺងម៉ាត់នូវវិធានការសុខាភិបាលរួមមាន ការពាក់ម៉ាស និងការរក្សាគម្លាតសុវត្ថិភាព ព្រមទាំងប្រកាន់ខ្ជាប់នូវការធ្វើអនាម័យ ដើម្បីសម្លាប់មេរោគ និងការវាស់កម្តៅ ដើម្បីប្រយុទ្ធនិងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩។

**ប្រការ៦** ..

សកម្មភាពផ្នែកប្រតិបត្តិការពាក់ព័ន្ធនឹងវិស័យអាកាសចរណ៍ស៊ីវិលនៅក្នុងតំបន់បិទខ្ទប់ (អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងមូលដ្ឋានការងារពាក់ព័ន្ធ) ត្រូវបានអនុញ្ញាតឱ្យដំណើរការជាធម្មតា។ ការធ្វើដំណើរពាក់ព័ន្ធនឹងវិស័យនេះ ត្រូវបានអនុញ្ញាត ដូចខាងក្រោម៖

- ការធ្វើដំណើររបស់អ្នកដំណើរតាមផ្លូវអាកាសទៅអាកាសយានដ្ឋាន ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់អត្តសញ្ញាណ និងឯកសារពាក់ព័ន្ធនឹងការធ្វើដំណើរ។ ចំពោះការធ្វើដំណើររបស់អ្នកដំណើរតាមផ្លូវអាកាសចេញពីអាកាសយានដ្ឋាន ត្រូវអនុវត្តតាមវិធានផ្នែកសុខាភិបាលជាធរមាន
- ការធ្វើដំណើររបស់មន្ត្រី និងបុគ្គលិកផ្នែកប្រតិបត្តិការដែលបម្រើការងារនៅអាកាសយានដ្ឋាន ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់អត្តសញ្ញាណ និងលិខិតបញ្ជាបេសកកម្ម ឬ លិខិតអនុញ្ញាតធ្វើដំណើររបស់រដ្ឋបាលរាជធានីភ្នំពេញ
- ការធ្វើដំណើររបស់មន្ត្រី និងបុគ្គលិកដែលបំពេញការងារបម្រើឱ្យការហោះហើរតាមផ្លូវអាកាស ត្រូវបានអនុញ្ញាតនៅក្នុងតំបន់បិទខ្ទប់ ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារបញ្ជាក់អត្តសញ្ញាណ និងលិខិតបញ្ជាបេសកកម្ម ឬ លិខិតអនុញ្ញាតធ្វើដំណើររបស់រដ្ឋបាលរាជធានីភ្នំពេញ ។

**ប្រការ៧** ..

**រដ្ឋបាលខណ្ឌទាំង១៤** មានភារកិច្ចសម្របសម្រួលលើការងារចាំបាច់ និងអនុវត្តវិធានការនានាចំពោះភូមិសាស្ត្រដែលត្រូវបានកំណត់ជា **"តំបន់ក្រហម" "តំបន់លឿងទុំ" និង "តំបន់លឿង"** ស្ថិតក្រោមដែនសមត្ថកិច្ចរៀងៗខ្លួន ក្នុងនោះ ក្រៅពីភារកិច្ចអនុវត្តវិធានការរដ្ឋបាលក្នុងការបិទខ្ទប់ ត្រូវបំពេញការងារអាទិភាព ជាអាទិ៍៖

- ការងារសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងគ្រប់គ្រងចរាចរណ៍ក្នុងភូមិសាស្ត្រខណ្ឌនីមួយៗ
- ការសម្របសម្រួល និងគាំទ្រចាំបាច់នានាដល់គណៈកម្មការចំពោះកិច្ចចាក់វ៉ាក់សាំងកូវីដ-១៩ ក្នុងក្របខណ្ឌទូទាំងប្រទេស **(គ.វ.ក-១៩)** និងស្ថាប័នពាក់ព័ន្ធនានា ក្នុងការជំរុញការអនុវត្ត **"យុទ្ធនាការជាតិចាក់វ៉ាក់សាំង"** ការពារជំងឺកូវីដ-១៩ ឱ្យបានលឿន ឆាប់រហ័ស និងប្រកបដោយប្រសិទ្ធភាព សម្រាប់ភូមិសាស្ត្រខណ្ឌនីមួយៗ
- ត្រៀមបម្រុង និងលើកសំណើឱ្យបានទាន់ពេលវេលា សម្រាប់ធានាឱ្យមានការផ្គត់ផ្គង់ស្បៀងចូលក្នុងភូមិសាស្ត្របិទខ្ទប់ក្នុងដែនសមត្ថកិច្ច និងការផ្តល់ជំនួយសង្គ្រោះបន្ទាន់ចាំបាច់នានា ជូនប្រជាពលរដ្ឋក្រីក្រ និងមានការលំបាកក្នុងជីវភាពនៅក្នុងភូមិសាស្ត្របិទខ្ទប់ ជាពិសេសនៅក្នុង **"តំបន់ក្រហម"**
- ត្រួតពិនិត្យ និងគ្រប់គ្រងទីកន្លែងលក់ម្ហូបអាហារ ទំនិញ អាជីវកម្មដ្ឋាន និងសេវាកម្មដែលជាតម្រូវការចាំបាច់ប្រចាំថ្ងៃ
- ការងារផ្តល់សេវាសុខាភិបាលទូទៅ និងអនុវត្តវិធានការសុខាភិបាល ជាអាទិ៍ ការយកសំណាក ការធ្វើចត្តាឡីស័ក និងការព្យាបាលជំងឺកូវីដ-១៩ ជាដើម ក្នុងភូមិសាស្ត្រខណ្ឌនីមួយៗ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ: (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh

ក្នុងករណីមានអ្នកវិជ្ជមានជំងឺកូវីដ-១៩ ក្នុង **"តំបន់លឿង"** រដ្ឋបាលខណ្ឌទាំង១៤ និងមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ ត្រូវចាត់វិធានការសុខាភិបាល និងវិធានការរដ្ឋបាលជាបន្ទាន់ ដោយត្រូវបិទទីតាំងជាផ្ទះ ឬ អគារ ឬ អាជីវកម្មដ្ឋាននោះ និងត្រូវកំណត់អ្នកពាក់ព័ន្ធដែលត្រូវយកសំណាកទៅវិភាគរកមេរោគកូវីដ-១៩ ព្រមទាំងត្រូវអនុវត្តវិធានចត្តាឡីស័ក ស្របតាមការណែនាំរបស់ក្រសួងសុខាភិបាល។

**ប្រការ៨ ..**

បុគ្គល ឬ នីតិបុគ្គលទាំងឡាយណា ដែលបំពានវិធានការហាមឃាត់ការធ្វើដំណើរ វិធានការហាមឃាត់សកម្មភាពការងារ មុខរបរ ឬ អាជីវកម្ម និងវិធានការហាមឃាត់រាល់ការជួបជុំ ឬ ការប្រមូលផ្តុំមនុស្ស ក្នុងភូមិសាស្ត្រ **"តំបន់ក្រហម" "តំបន់លឿងទុំ"** និង **"តំបន់លឿង"** នឹងត្រូវអនុវត្តវិធានការច្បាប់យ៉ាងម៉ឺងម៉ាត់ ដោយរួមទាំងការឃាត់ទុកជាបណ្តោះអាសន្ននូវមធ្យោបាយធ្វើដំណើរ និងទណ្ឌកម្មរដ្ឋបាល ដោយអនុលោមតាមបទប្បញ្ញត្តិ និងនីតិវិធីជាធរមាន។

បន្ថែមលើវិធានការខាងលើ បុគ្គល ឬ នីតិបុគ្គលទាំងឡាយណា ដែលមិនអនុវត្តតាម**ប្រការ៣ ប្រការ៤ ប្រការ៥ និងប្រការ៦** នៃសេចក្តីសម្រេចនេះ នឹងត្រូវកសាងសំណុំរឿងបញ្ជូនទៅស្ថាប័នតុលាការ ដើម្បីផ្តន្ទាទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់ ស្របតាម**មាត្រា១០** និង**មាត្រា១១** នៃច្បាប់ស្តីពីវិធានការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ និងជំងឺឆ្លងកាចសាហាវ និងប្រកបដោយគ្រោះថ្នាក់ធ្ងន់ធ្ងរផ្សេងទៀត និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**ប្រការ៩ ..**

បទប្បញ្ញត្តិទាំងឡាយណា ដែលបានដាក់ចេញដើម្បីប្រយុទ្ធ និងទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ មុនពេលសេចក្តីសម្រេចនេះចូលជាធរមាន ហើយដែលមិនផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវមានអនុភាពអនុវត្តបន្តរហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ ..**

នាយករដ្ឋបាលសាលារាជធានីភ្នំពេញ ស្នងការនគរបាលរាជធានីភ្នំពេញ មេបញ្ជាការកងរាជអាវុធហត្ថរាជធានីភ្នំពេញ អភិបាល នៃគណៈអភិបាលខណ្ឌទាំង១៤ ប្រធានមន្ទីរសុខាភិបាលនៃរដ្ឋបាលរាជធានីភ្នំពេញ ប្រធានមន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ៕

ថ្ងៃ ពុធ ៩ រោច ខែពិសាខ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែឧសភា ឆ្នាំ២០២១

**អភិបាលរាជធានីភ្នំពេញ**

**ឃួង ស្រេង**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងសុខាភិបាល
- គ្រប់ក្រសួង-ស្ថាប័ន
- ក្រុមប្រឹក្សារាជធានីភ្នំពេញ

*«ដើម្បីគោរពជូនជ្រាប»*

- ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ
- បញ្ជាការដ្ឋានកងរាជអាវុធហត្ថរាជធានីភ្នំពេញ
- រដ្ឋបាលខណ្ឌទាំង១៤
- មន្ទីរ-អង្គភាពជំនាញជុំវិញរដ្ឋបាលរាជធានីភ្នំពេញ
- ដូចប្រការ១០

*«ដើម្បីមុខការ»*

- គ្រប់ប្រព័ន្ធផ្សព្វផ្សាយ

*«ដើម្បីជួយផ្សព្វផ្សាយ»*

- ឯកសារ-កាលប្បវត្តិ



៦៩មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥)២៣-៧២២ ៧៣៩ / ទូរសារ: (៨៥៥)២៣-៧២៥ ៦២៦ / ២៣-៧២២ ០៥៤
www.phnompenh.gov.kh; Email : info@phnompenh.gov.kh